ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿង ព្រហ្មទណ្ឌ

លេខ : ៤៥

ចុះថ្ងៃទី០២ខែសីហា ឆ្នាំ១៩៩៩

សាលដីកា

លេខ : ៣០

ចុះថ្ងៃទី០៦ខែតុលា ឆ្នាំ១៩៩៩

ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ខែ តុលា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្តី ជាប្រធាន

២- លោក ឈឹម ស៊ីផល ជាចៅក្រម

៣- លោក សោម សិរីវឌ្ឍ ជាចៅក្រមរបាយការណ៍

៤- លោក ប្រាក់ គឹមសាន ជាចៅក្រម

៥- លោក យស់ សួខឿន ជាចៅក្រម

លោក ខាន់ បូរ៉ាត ជាក្រឡាបញ្ជី

តំណាងមហាអយ្យការលោក ជួន ស៊ុនឡេង ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ១៥៣ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ៤៥ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ-១៩៩៩ របស់តុលាការកំពូល ។

ពីបទ : បំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ប្រព្រឹត្តនៅភូមិសុវណ្ណសាគរ ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត កាលពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩៩ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះ ស៊ុំ ឈឿន "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤៤ ឆ្នាំ ជាតិ ខ្មែរក្រោម កើតនៅភូមិឃ្លាំង ឃុំហ្វាង ប្រទេសវៀតណាម សាសនាព្រះពុទ្ធ មុខរបរ លក់នំប៉័ង ទីលំនៅភូមិសុវណ្ណសាគរ ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត ។ ឪពុកឈ្មោះ ជឿង "ស្លាប់" ម្តាយឈ្មោះ ចាន់ ស៊ិន "ស្លាប់" ប្តីឈ្មោះ យ៉ឹន រ៉ា មានកូន០៣នាក់ ។ ចាប់ខ្លួនថ្ងៃទី ១៨-៥-៩៩ ឃុំខ្លួនថ្ងៃទី ១៨-៥-៩៩ ។

- មេធាវីលោក មួង អរុណា

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ នួង ស្រីអឹម "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤៣ឆ្នាំ ជាតិ ខ្មែរ សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃនៅភូមិ ក្រាំង ឃុំក្រាំងអំពិល ស្រុកកំពង់បាយ ខេត្តកំពត ឪពុកឈ្មោះ នួង ប៉ុយ "រស់" ម្តាយឈ្មោះ ស៊ីវ ចាយ "រស់" ប្តីឈ្មោះ អ៊ុន សាវ៉ាត់ផាន មានកូន ០៥ នាក់ ។ មេធាវី គ្មាន ។

- តាមពាក្យបណ្តឹងចុះថ្ងៃទី ០៥-៥-៩៩ របស់ឈ្មោះ នួង ស្រីអឹម គឺតទុកមិនសុខចិត្តពី ឈ្មោះ ស៊ុំ យឿន ដែលបានរុះរើផ្ទះ ខូចទ្រង់ទ្រាយ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ខ្លួន ដែលខ្លួនបាន ជួលអោយកាលពីថ្ងៃទី ១០-០១-៩៥ នោះ ។ ខ្លួនសុំទាមទារសំណងការខូចខាតពីស៊ុំ យឿន ចំនួន ៥.០០០ដុល្លារ ។

- បានឃើញដីកាឃុំខ្លួនលេខ ៥៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពត ។

- បានឃើញដីកាសំរេចមិនអោយជនល្មើសនៅក្រៅឃុំបណ្តោះអាសន្នលេខ ៤០១ ចុះថ្ងៃទី- ៣១ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តកំពត ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់លោក ជុំ- សោភា មេធាវីការពារអោយជនជាប់ចោទ ដែលប្តឹងតវ៉ាពី ដីកាសំរេចមិនអោយជនល្មើសនៅក្រៅឃុំបណ្តោះអាសន្ន លេខ ៤០១ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់ចៅក្រមស៊ើបអង្កេត លើ ដីកាសំរេចទាំងមូល ។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា:

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៣១-៥-៩៩ របស់មេធាវី ជុំ សោភា ធ្វើឡើង ត្រឹមត្រូវតាមទំរង់ច្បាប់ បដិសេធចោលដោយខុសពីនីតិច្បាប់ ។

២- តម្កល់ដីកាសំរេចលេខ ៤០១ ចុះថ្ងៃទី ៣១-៥-៩៩ របស់តុលាការខេត្តកំពត ទុកជាបានការពេញទាំងមូល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៥៣ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេច :

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៣១-៥-៩៩ របស់លោក ជុំ សោភា មេធាវីការពារ ជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងនីតិច្បាប់ ។

២- តម្កល់ដីកាសំរេចមិនអោយជនល្មើសនៅក្រៅឃុំបណ្តោះអាសន្នលេខ ៤០១ ចុះថ្ងៃទី- ៣១-៥-៩៩ របស់ចៅក្រមស៊ើបអង្កេត នៃតុលាការខេត្តកំពត ទុកជាបានការពេញទាំងមូល ។

សាលដីកា នេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខមេធាវីរបស់ជនជាប់ចោទ កំបាំងមុខជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពអនុវត្ត ទោះជាមានបណ្តឹងសាទុក្ខក៏ដោយៗ

- បានឃើញបណ្តឹងសាទុក្ខលេខ ២០ ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ១៩៩៩ របស់ជនជាប់ចោទ ឈ្មោះ ស៊ុំ យឿន ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៥៣ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៩

របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី០៧ ខែ សីហា ឆ្នាំ ១៩៩៩ របស់ឈ្មោះស៊ុំ យឿន ជាម្ចាស់បណ្តឹងសាទុក្ខ " ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៩ របស់ឈ្មោះ ស៊ួង-ស្រីស៊ុម " ជាចុងបណ្តឹងសាទុក្ខ " ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: បទល្មើសនេះ ជាបទល្មើសមជ្ឈិមមែនពិត ប៉ុន្តែការឃុំខ្លួនជនជាប់ចោទនាំហួសរយៈពេលកំណត់ ហើយបទល្មើសនេះ គ្មានភស្តុតាងច្បាស់លាស់ក្នុងការស៊ើបអង្កេតឡើយ បើយោងតាមមាត្រា ២២ គួរយល់ព្រមអោយជនជាប់ចោទនៅក្រៅឃុំបណ្តោះអាសន្ន ។

- បានស្តាប់អំណានសារណារបស់ ម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ

- បានស្តាប់អំណានសារណាឆ្លើយតបរបស់ ចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក មួង អនុរា ជាមេធាវីការពារអោយជនជាប់ចោទ នៅពេលជំនុំជំរះថា: ក្នុងរឿងនេះតុលាការថ្នាក់ក្រោម ពុំទាន់បានពិនិត្យ និងស្រាវជ្រាវអោយបានគ្រប់គ្រាន់ផង ក៏សំរេចឃុំខ្លួនកូនក្តីខ្ញុំបាទដោយបំពានច្បាប់ ។ តាមការពិតដីទំនាស់នោះឈ្មោះ ស៊ុំ យឿន បានរស់នៅតាំងពីឆ្នាំ ១៩៨០-៨១ មកម្លេះ ។ ម្យ៉ាងទៀត តុលាការពុំទាន់មានសាលក្រមកំណត់ថាដីនោះជារបស់នរណាផង ។ ឯការរុះរើផ្ទះ គឺផ្ទះរបស់គាត់លិចធ្លុះធ្លាយពេលភ្លៀងម្តងពិបាកការសំរាក គាត់រុះរើដើម្បីជួសជុល ដោយបានសុំការអនុញ្ញាតពីរដ្ឋអំណាចផងដែរ ។

ខ្ញុំបាទសូមគោរព សូមតុលាការមេត្តាអនុញ្ញាត អោយកូនក្តីរបស់ខ្ញុំបាទ បាននៅក្រៅឃុំបណ្តោះអាសន្នដោយអនុគ្រោះ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ របស់ដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៦០ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ១៩៩៩ របស់ឈ្មោះ ស៊ុំ យឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការបង្កើតតាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់ដីកាសំរេចមិនអោយជនល្មើសនៅក្រៅឃុំបណ្ដោះអាសន្នលេខ ៤០១ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៩ ដោយមូលហេតុជនល្មើសគ្មានលំនៅ ច្បាស់លាស់នោះពុំជាការត្រឹមត្រូវហើយ ។ ក៏ប៉ុន្តែសាលាឧទ្ធរណ៍បានបំពានទៅលើចំណុចមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដោយពុំបានគោរពរយៈពេល១៥ថ្ងៃដែលសាលា-ឧទ្ធរណ៍ត្រូវសំរេចលើពាក្យសុំឧទ្ធរណ៍ទាំងឡាយទាក់ទិនក្នុងរឿងឃុំខ្លួននេះ ។

- យល់ឃើញថា ការមិនបានគោរពតាមនីតិវិធីដូចបានលើកឡើងខាងលើនេះ នាំអោយមានការដោះលែងជនជាប់ចោទអោយមានសេរីភាពជាបណ្ដោះអាសន្នបាន តាមមាត្រា២២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- យល់ឃើញថា ជនជាប់ចោទនិងដើមបណ្ដឹងរដ្ឋប្បវេណី បានធ្វើសារណាជូនមកតុលាការកំពូល ព្រមទាំងបានទទួលដីកានោះហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៥៣ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខមេធាវីជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្ដឹងសាទុក្ខលេខ ៦០ ចុះថ្ងៃទី០៧ខែកក្កដាឆ្នាំ ១៩៩៩របស់ឈ្មោះ ស៊ុំ ហឿន ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ១៥៣ចុះថ្ងៃទី១៦ខែមិថុនាឆ្នាំ ១៩៩៩របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - សំរេចអោយជនល្មើសឈ្មោះស៊ុំ ហឿននៅក្រៅឃុំបណ្ដោះអាសន្នតាមពាក្យសុំ ។

៤ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៤៥ ចុះថ្ងៃទី០២ខែសីហាឆ្នាំ១៩៩៩ របស់តុលាការកំពូលទៅតុលាការខេត្តកំពត ដើម្បីចាត់ការតាមនីតិវិធី ។

៥ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៦ខែតុលាឆ្នាំ១៩៩៩។